雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团
No.138

# ប្រទេសចិន-ខេត្តយូនណាន

ទស្សនាវដ្តី ប្រចាំខែ

YUNNAN DAILY PRESS GROUP
english.yunnan.cn

ឆ្នាំទី 26 លេខ 7527 ថ្ងៃសុក្រ ទី 05 ខែមករា ឆ្នាំ 2018

# កិច្ចសហប្រតិបត្តិការទេសចរណ៍ចិន-កម្ពុជា ឈានដល់កម្រិតខ្ពស់ថ្មីមួយទៀតនៅឆ្នាំ២០១៧

ឆ្នាំ២០១៧ គឺជាឆ្នាំដ៏សំខាន់មួយ ដែលប្រទេសចិន និងកម្ពុជាបានទទួលនូវលទ្ធផលជាផ្លែផ្កា ក្នុងការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ ។ ក្នុងអំឡុងពេលពីខែមករាដល់ខែវិច្ឆិកា ឆ្នាំ២០១៧ ប្រទេសកម្ពុជាបានទទួលទេសចរចិនលើសពីមួយលាននាក់ ដែលបានធ្វើឱ្យប្រទេសចិនក្លាយទៅជាប្រភពទេសចរធំជាងគេរបស់កម្ពុជា ។

លោក ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍កម្ពុជាបានផ្តល់សម្ភាសន៍ជាមួយអ្នកកាសែតថា ក្នុងអំឡុងពេលពីខែមករាដល់ខែតុលា ឆ្នាំ២០១៧ ប្រទេសកម្ពុជាបានទទួលទេសចរអន្តរជាតិប្រមាណ៤,៣លាននាក់ កើនឡើង ១០ភាគរយ ។ ក្នុងនោះទេសចរចិនមានចំនួន៩,៥សែននាក់ កើនឡើង៤៥ភាគរយ ស្មើនឹង២២ភាគរយនៃចំនួនទេសចរអន្តរជាតិដែលទៅធ្វើទេសចរណ៍នៅប្រទេសកម្ពុជា ។ លោកបានសង្កត់ធ្ងន់ថា ឆ្នាំ២០១៧ ជារយៈកាលដ៏មានសារសំខាន់ក្នុងការអភិវឌ្ឍទំនាក់ទំនងទេសចរណ៍រវាងប្រទេសទាំងពីរកម្ពុជា-ចិន ។

លោក វ៉ៃ ជីម៉េង អគ្គលេខាធិការនៃសភាពាណិជ្ជកម្មចិននៅប្រទេសកម្ពុជាសាខាសៀមរាបបានប្រាប់អ្នកកាសែតថា សព្វថ្ងៃមានទេសចរចិនកាន់តែច្រើនមកដើរលេងខេត្តសៀមរាប ជាពិសេសទីនេះក៏បានទាក់ទាញវិនិយោគិនចិនកាន់តែច្រើនដែរ ។ កាលពីមុន ពួកគេមកបង្កើតក្រុមហ៊ុនទេសចរណ៍ ឬបើកភោជនីយដ្ឋាននិងសណ្ឋាគារ តែបច្ចុប្បន្នពួកគេកំពុងខិតខំអភិវឌ្ឍន៍ផលិតផលទេសចរណ៍គ្រប់ប្រភេទ ដែលបានជំរុញការអភិវឌ្ឍនៃសេដ្ឋកិច្ច និងសង្គមកម្ពុជា ។



*អ្នកទេសចរជនជាតិចិនថតរូប នៅមុខព្រះបរមរាជវាំងនៃកម្ពុជា*
*(ដោយ Mao Pengfei អ្នកថតរូប Xinhua )*

កម្មវិធីសម្តែងសិល្បៈ "រាជវង្សអង្គរ" ដែលរៀបចំដោយភាគីចិននិងកម្ពុជានោះ បានចាប់ផ្តើមសម្តែងជាផ្លូវការក្នុងរោងល្ខោនអង្គរនៅខែតុលា ឆ្នាំ២០១៧ ។ រោងល្ខោនអង្គរជារោងល្ខោនពិសេស ដែលត្រូវសាងសង់ឡើងដើម្បីសម្តែងកម្មវិធីសិល្បៈ "រាជវង្សអង្គរ" នេះហើយ ជារោងល្ខោនដែលមានមុខងារចម្រុះ រួមមានការសម្តែងកម្មវិធីសិល្បៈ ពាណិជ្ជកម្ម និងការលេងកម្សាន្ត ហើយក្នុងនោះក៏មានភោជនីយដ្ឋានសម្រាប់ទស្សនិកជនដែរ ។ បន្ទាប់ពីរោងល្ខោននេះត្រូវដំណើរការប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី៨ ខែធ្នូ រៀងមក លោកស្រីម៉ែន សំអន ឧបនាយករដ្ឋមន្ត្រីកម្ពុជា លោកស្រី ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈកម្ពុជា លោក ឃឹម ប៊ុនសុង អភិបាលខេត្តសៀមរាប ព្រមទាំងទស្សនិកជនជាតិ និងអន្តរជាតិសរុបជាងមួយម៉ឺននាក់ បានអញ្ជើញទៅទស្សនាកម្មវិធីសម្តែងសិល្បៈក្នុងរោងល្ខោននេះ ។ បច្ចុប្បន្នរោងល្ខោននេះបានក្លាយទៅជាកន្លែងទេសចរណ៍ដ៏សំខាន់មួយទៀតរបស់ប្រទេសកម្ពុជា ។

គួរបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការមួយចំនួនធំ ដើម្បីទាក់ទាញទេសចរចិនឱ្យបានកាន់តែច្រើន ដូចជាលើកទឹកចិត្តឱ្យប្រើប្រាស់ប្រាក់យ័នចិន បន្ថែមស្លាកភាសាចិននៅកន្លែងទេសចរណ៍ និងបណ្តុះបណ្តាលមគ្គុទ្ទេសក៍ដែលចេះនិយាយភាសាចិនជាដើម ។

លោកថោង ខុនមានប្រសាសន៍ថា នៅឆ្នាំ២០១៧ ទេសចរចិនបាននាំមកនូវចំណូលប្រមាណ៧០០លានដុល្លារអាមេរិកដល់ប្រទេសកម្ពុជា ដែលបានដើរតួនាទីសំខាន់ក្នុងការ អភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រនៃប្រទេសកម្ពុជា ។ កម្ពុជាគ្រោងទទួលទេសចរអន្តរជាតិប្រាំពីរលាននាក់នៅឆ្នាំ២០២០ដែលនឹងអាចនាំមកនូវចំណូល៥.០០០លានដុល្លារអាមេរិកនិងផ្តល់ឱកាសការងារដល់ប្រជាជនខ្មែរជាងមួយលាននាក់ ។ ក្នុងចំណោមនោះ កម្ពុជាសង្ឃឹមថា នឹងអាចមានទេសចរចិនពីរលាននាក់ ។ លោកបានបញ្ជាក់ទៀតថា "យើងខ្ញុំមានសុទិដ្ឋិនិយមចំពោះការសម្រេចនូវគោលដៅនេះ" ៕

**ដោយ ម៉ាវ ភឹងហ្វី (ស៊ីនហួ ចិន)**

# រថភ្លើងល្បឿនលឿនសញ្ញា "ដើបឡើងវិញ" ដាក់ឱ្យប្រើប្រាស់នៅខេត្តយូនណានជាលើកដំបូង




*រទេះភ្លើងល្បឿនលឿន ធុខិនង កំពុងតែត្រៀមខ្លួនចាកចេញពីស្ថានីយភាគខាងត្បូងគុនមីង (រូបថតដោយHu Xiaorong )*

នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ វេលាម៉ោង៨:១៤នាទី រថភ្លើងលេខ G១៣៧២ (គុនមីង-សៀងហៃ) បានចេញដំណើរពីស្ថានីយរថភ្លើងខាងត្បូង ក្រុងគុនមីងទៅក្រុងសៀងហៃ ។ រថភ្លើងនេះជារថភ្លើងល្បឿនលឿនសញ្ញា "ដើបឡើងវិញ" ដែលត្រូវបានប្រើប្រាស់ជាលើកទី១ នៅថ្ងៃទី២១ ខែកញ្ញា តាមខ្សែរថភ្លើងគុនមីង-សៀងហៃនេះ ។ គួរបញ្ជាក់ថា រថភ្លើងប្រភេទថ្មីនេះអាចធ្វើដំណើរក្នុងល្បឿនយ៉ាងលឿន គឺ៣៥០គីឡូម៉ែត្រ/ម៉ោង ។

រថភ្លើងសញ្ញា "ដើបឡើងវិញ" ជារថភ្លើងល្បឿនលឿន ដែលសិក្សាស្រាវជ្រាវដោយសហគ្រាស សាកលវិទ្យាល័យ និងស្ថាប័នសិក្សាស្រាវជ្រាវចិន ក្រោមការសម្របសម្រួលរបស់ក្រុមហ៊ុនផ្លូវដែកចិន ។ រថភ្លើងប្រភេទនេះបានប្រើប្រាស់បច្ចេកទេសថ្មី និងជឿនលឿន ហើយអាចធ្វើដំណើរបានក្នុងល្បឿន៣៥០គីឡូម៉ែត្រ/ម៉ោង ។ ជាពិសេស វាមានឧត្តមភាពលើវិស័យការពារសុវត្ថិភាពសំចៃថាមពល និងថែរក្សាបរិស្ថានជាដើម ។ តាមការឧទ្ទេសនាមបានឱ្យដឹងថា រថភ្លើងប្រភេទថ្មីនេះបានបំពាក់ដោយបណ្តាញ WiFi និងថាមពលអគ្គិសនីសម្ពាធ ២២០V ព្រមទាំងប្រព័ន្ធកែសម្រួលសម្ពាធខ្យល់ក្នុងទូរថភ្លើង ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកដំណើរគ្រប់ៗគ្នា ។

ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ ជាខួបគម្រប់មួយឆ្នាំនៃការដំណើរការប្រើប្រាស់ខ្សែរថភ្លើងល្បឿនលឿននៅខេត្តយូនណាន ។ ក្នុងរយៈពេលមួយឆ្នាំកន្លងទៅនោះ ខ្សែរថភ្លើងល្បឿនលឿននៃខេត្តយូនណានបានផ្តល់សេវាកម្មដល់អ្នកដំណើរ១២,០២លាននាក់ ហើយគិតជាមធ្យមមានរថភ្លើងល្បឿនលឿន៧២គូធ្វើដំណើរទៅមកជារៀងរាល់ថ្ងៃ ៕ **ដោយ ហ៊្វូ សៀវយ៉ុង**

# វិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈអន្តរជាតិឡានឆាង-មេគង្គ ប្រទេសទាំង៦រួមគ្នាពិគ្រោះពិភាក្សាស្ថាបនា និងចែករំលែកគ្នា

**សង្ខេប:** វិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈអន្តរជាតិឡានឆាង-មេគង្គ ស្ថិតនៅក្នុងតំបន់អភិវឌ្ឍន៍សេដ្ឋកិច្ចវ៉ានឌីង នៃក្រុងយូយលី មណ្ឌលស្វយ័តជនជាតិតៃ និងជីងភ្ពួ តឺហុង ខេត្តយូនណាន ។ វិទ្យាស្ថាននេះត្រូវបង្កើតឡើងដោយសាកលវិទ្យាល័យជនជាតិខេត្តយូនណាន និងសាលារដ្ឋបាលក្រុងយូយលី ហើយជាសាលារដ្ឋមួយដែលផ្តល់ការអប់រំថ្នាក់បរិញ្ញាបត្រ និងជាវិទ្យាស្ថានក្រោមចំណុះសាកលវិទ្យាល័យជនជាតិខេត្តយូនណាន ។ វិទ្យាស្ថាននេះទទួលបន្ទុកបណ្តុះបណ្តាលធនធានមនុស្សគុណភាពខ្ពស់ ដើម្បីបំពេញតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមក្នុងតំបន់ទន្លេឡានឆាង-មេគង្គ ។ គួរបញ្ជាក់ថា វិទ្យាស្ថាននេះជាវិទ្យាស្ថានអន្តរជាតិមួយដែលផ្តោតសំខាន់ទៅលើការអប់រំថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្ររង ហើយក៏ផ្តល់ការអប់រំនិងការបណ្តុះបណ្តាលក្រៅប្រព័ន្ធដែរ ។

នៅថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៧ វិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈអន្តរជាតិឡានឆាង-មេគង្គ បានប្រារព្ធពិធីបញ្ចុះបឋមសិលា និងបើកការដ្ឋានសាងសង់នៅក្រុងយូយលី មណ្ឌលស្វយ័តជនជាតិតៃ និងជីងភ្ពួ តឺហុង ខេត្តយូនណាន ។

ព្រឹត្តិការណ៍នេះ ជាសមិទ្ធផលដ៏សំខាន់មួយរបស់ខេត្តយូនណានក្នុងការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទន្លេឡានឆាង-មេគង្គ ហើយ ក៏បានបើកទំព័រថ្មីនៃការធ្វើកិច្ចសហប្រតិបត្តិការអំពីការបណ្តុះបណ្តាលវិជ្ជាជីវៈតាមប្រទេសទន្លេឡានឆាង-មេគង្គដែរ ។

តើហេតុអ្វីបានជាត្រូវបង្កើតវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈអន្តរជាតិឡានឆាង-មេគង្គនេះ ? លោក មីមី អោង (MiMi Aung) សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភាសាបរទេសរ៉ុងហ្គូនប្រទេសមីយ៉ាន់ម៉ា បានបញ្ជាក់ថា បច្ចុប្បន្នការអភិវឌ្ឍប្រទេសមួយមិនត្រឹមតែត្រូវពឹងផ្អែកលើធនធានធម្មជាតិ និងការរីកចម្រើននៃសេដ្ឋកិច្ចប៉ុណ្ណោះទេ ចំណែកគុណភាពធនធានមនុស្សពិតជាមានសារសំខាន់ណាស់ ។

លោក សាយខាំ ផាន់ថាវង្ស (SaykhamPhanthavong) លេខាធិការគណបក្ស និងជានាយកវិទ្យាស្ថានបច្ចេកទេសបាបាសា ក្រុងវៀងចន្ទន៍ ប្រទេសឡាវ បានលើកមតិថា កិច្ចសហប្រតិបត្តិការលើវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈមានទំនាក់ទំនងជិតស្និទ្ធទៅនឹងការអភិវឌ្ឍនៃប្រទេសនីមួយៗ និងតំបន់ទាំងមូល ។ ក្រោមក្របខ័ណ្ឌយន្តការសហប្រតិបត្តិការឡានឆាង-មេគង្គ យើងទាំងអស់គ្នាត្រូវជំរុញឱ្យការបណ្តុះបណ្តាលវិជ្ជាជីវៈដើរតួនាទីកាន់តែសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដើម្បីកសាងអនាគតដ៏ភ្លឺស្វាងនៃការអភិវឌ្ឍដោយចីរភាពក្នុងតំបន់ និងសម្រាប់ប្រជាជនម្នាក់ៗ ។

ការអភិវឌ្ឍ និងពង្រឹងកិច្ចសហប្រតិបត្តិការអំពីការបណ្តុះបណ្តាលវិជ្ជាជីវៈ គឺជាក្តីបំណងរួមរបស់ប្រទេសទន្លេឡានឆាង-មេគង្គទាំង ៦ គឺប្រទេសឡាវ ថៃ កម្ពុជា មីយ៉ាន់ម៉ា វៀតណាម និងចិន ។ ដូច្នេះ នៅខែធ្នូ ឆ្នាំ២០១៦ ក្រោមការគាំទ្រពីក្រសួងអប់រំចិន ក្រសួងការបរទេសចិន និងសាលារដ្ឋបាលខេត្តយូនណាន សាកលវិទ្យាល័យជនជាតិខេត្តយូនណានបានបង្កើតវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈអន្តរជាតិឡានឆាង-មេគង្គជាផ្លូវការ ។




*ពិធីចុះបឋមសិលាបើក វិទ្យាស្ថានអន្តរជាតិ*

លោក ឈឹន លូយ៉ាន លេខាធិការគណបក្សនៃសាកលវិទ្យាល័យជនជាតិខេត្តយូនណាន បានមានប្រសាសន៍ថា ការបណ្តុះបណ្តាលវិជ្ជាជីវៈ គឺជាប្រព័ន្ធអប់រំ ដែលអាចធ្វើឱ្យមនុស្សធម្មតាបញ្ចេញភាពទាក់ទាញ ធ្វើឱ្យប្រជាជនទទួលបាននូវជីវភាពធូរធារ និងធ្វើឱ្យឧស្សាហកម្មរីកចម្រើនកាន់តែឆាប់រហ័ស ។ ការបង្កើតវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈអន្តរជាតិឡានឆាង-មេគង្គនេះនឹងអាចផ្តល់ផលប្រយោជន៍ដល់បណ្តាប្រទេសពាក់ព័ន្ធ តាមរយៈការផ្លាស់ប្តូរបទពិសោធន៍អំពីការបណ្តុះបណ្តាលវិជ្ជាជីវៈ:បណ្តុះបណ្តាលធនធានមនុស្សបច្ចេកទេសកាន់តែច្រើន និងជំរុញការធ្វើសមាហរណកម្មវិស័យអប់រំ វប្បធម៌ និងឧស្សាហកម្មនៃប្រទេសទន្លេឡានឆាង-មេគង្គទាំង ៦ ។

លោក ចាវ យូយឃឹន អភិបាលរងនៃក្រុងយូយលី បានថ្លែងថា ការបង្កើតវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈអន្តរជាតិឡានឆាង-មេគង្គនៅក្រុងយូយលី មានសារសំខាន់សម្រាប់ជំរុញការអភិវឌ្ឍ និងការបើកទូលាយរបស់ក្រុងយូយលី ។ ការអភិវឌ្ឍ ឧស្សាហកម្មត្រូវតែមានធនធានមនុស្ស ដែលមានគុណភាពខ្ពស់ ។ ដូច្នេះការ បង្កើតវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈអន្តរជាតិឡានឆាង-មេគង្គ នៅក្រុងយូយលីនឹងអាចជួយក្រុងយូយលី និងបណ្តាប្រទេសនានាក្នុងតំបន់អាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូងបណ្តុះបណ្តាលធនធានមនុស្សឱ្យបានកាន់តែច្រើន ដើម្បីជំរុញការអភិវឌ្ឍនៃឧស្សាហកម្ម ។

រូបមន្ត "១+៦+៦+៦+N " ជារូបមន្តអភិវឌ្ឍសំខាន់របស់វិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈអន្តរជាតិឡានឆាង-មេគង្គ។ ពាក្យថា "១"គឺសំដៅទៅលើការបង្កើតមូលដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈ និងសហព័ន្ធ បណ្តុះបណ្តាលវិជ្ជាជីវៈទន្លេឡានឆាង-មេគង្គ។ កិច្ចការនេះត្រូវតែមានការចូលរួមពីរដ្ឋាភិបាលនៃប្រទេសទាំង៦ និងសាកលវិទ្យាល័យលំដាប់លេខ ១ នៃប្រទេសទាំង ៦ ហើយត្រូវបង្កើតក្រុមប្រឹក្សារួមដោយប្រទេសទាំង៦។ចំណែកអក្សរ "N"តំណាងឱ្យក្រុមហ៊ុនសហគ្រាសសាលារៀន និងស្ថាប័នសិក្សាស្រាវជ្រាវផ្សេងៗដែលអាចផ្តល់ការគាំទ្រដល់ការអភិវឌ្ឍនៃវិទ្យាស្ថាននេះ ។

លោក យីន ស៊ីថាង នាយកវិទ្យាស្ថាន បណ្តុះបណ្តាលវិជ្ជាជីវៈអន្តរជាតិឡានឆាង-មេគង្គ បានគូសបញ្ជាក់ថា ប្រទេសទន្លេឡានឆាង-មេគង្គមានឧត្តមភាពផ្នែកធនធានធម្មជាតិក្នុងការអភិវឌ្ឍវិស័យកសិកម្ម តែនៅមានកង្វះខាតផ្នែកបច្ចេកទេស ។ នាពេលខាងមុខ វិទ្យាស្ថានយើងនឹងបង្កើតមុខវិជ្ជាពាក់ព័ន្ធនឹងវិស័យកសិកម្ម ហើយជ្រើសរើសសិស្សបរទេសឱ្យមករៀនភាសាចិន រួចបញ្ជូនពួកគេទៅរៀនមុខវិជ្ជាឯកទេសក្នុងសាលាបច្ចេកទេសជំនាញដែលជាដៃគូសហប្រតិបត្តិការរបស់យើង ។ នៅខែកញ្ញា ឆ្នាំ ២០១៨ វិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈអន្តរជាតិឡានឆាង-មេគង្គនឹងចាប់ផ្តើមជ្រើសរើសសិស្សពីប្រទេសទន្លេមេគង្គទាំង៥ ហើយបង្កើតកម្មវិធីសិក្សាជំនាញតាមតម្រូវការអភិវឌ្ឍនៃក្រុងយូយលី និងបណ្តាប្រទេសជិតខាងនានា ។

កិច្ចសហប្រតិបត្តិការអំពីការបណ្តុះបណ្តាលវិជ្ជាជីវៈរវាងប្រទេសទន្លេឡានឆាង-មេគង្គកំពុងរីកចម្រើនទៅមុខជាលំដាប់ ។ នាវាអប់រំដែលប្រទេសទាំង ៦ រួមគ្នាពិគ្រោះពិភាក្សាស្ថាបនា និងចែករំលែកគ្នាកំពុងតែ ធ្វើដំណើរទៅមុខយ៉ាងរលូនតាមទន្លេឡានឆាង-មេគង្គ ដើម្បីព្រោះគ្រាប់ពូជមិត្តភាព និងគ្រាប់ពូជនៃក្តីសង្ឃឹមតាមបណ្តាប្រទេសនានា ព្រមទាំងនាំមកនូវជីវភាពរស់នៅដ៏ល្អប្រសើរជូនដល់ប្រជាជននៃប្រទេសទាំង ៦ ៕

**ដោយ ហាន ឈើងយាន់ និង ស៊ូ ឈូយ៉ាន**
**-ការវាយតម្លៃ**

លោកកុងស៊ុល នៃស្ថានអគ្គកុងស៊ុលប្រទេសកម្ពុជា ប្រចាំនៅក្រុងគុនមីង មានប្រសាសន៍ថា ប្រទេសទន្លេឡានឆាង-មេគង្គត្រូវតែពង្រឹងកិច្ចសហប្រតិបត្តិការពហុវិស័យ ជាពិសេសលើវិស័យបណ្តុះបណ្តាលធនធានមនុស្ស ពីព្រោះវិស័យនេះមានសារសំខាន់ណាស់ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ។ ដូច្នេះការបង្កើតវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ អន្តរជាតិឡានឆាង-មេគង្គនេះពិតជាមានសារសំខាន់សម្រាប់ការអភិវឌ្ឍនៃតំបន់ទន្លេឡានឆាង-មេគង្គ ៕